

## ផ្ទះកក់ក្តៅ គ្រួសារសុខសាន្ត

វគ្គ៖

# អត្ថប្រយោជន៍នៃ លេខសេវាអតិថិជន


អាឡូ បងឈ្មោះ កូលាប មែនទេ?
ចា៎! ខ្ញុំហ្នឹងហើយ កូលាប!
ខល ពីខាងណា? មានការ អីដែរ?
ខ្ញុំខលពី ស្ថាប័នដែល បងខ្ចីប្រាក់
ខាងយើង មានកម្មវិធីសម្រួល ដល់ការបង់ប្រចាំ ខែរបស់បង


ប្រសិន
បើបងបង់
៨០០ ដុល្លារ
ក្នុងថ្ងៃនេះ យើង
នឹងអនុញ្ញាតិឲ្យ
បងផ្អាកការបង់
៦ខែ
ដូចជា
មិនលឺលោក
គ្រូអាវទឹកក្រូច
ប្រាប់ពីរឿង
នេះ?!
លោកគ្រូ
គាត់ឈប់
ហើយ
បើមិនជឿ
បងអាចតេទៅ
ការិយាល័យ លេខ
012 345 678
បាន


ចុម!
តាមចាំ ដូច
មិនមែនលេខ
ហ្នឹង?!


ឈ្មោះជាភាសាអង់គ្លេស:
លេខគណនីអតិថិជន:
ប្រាក់រៀល
ប្រាក់ដុល្លារ
បង់តាមភ្នាក់ងារវីង ឬទ្រូម៉ានី ដោយឥតគិតថ្លៃ ករណីយកថ្លៃសេវាសូមទាក់ទងលេខខាងក្រោម
ប្រសិនប្រើលោកអ្នករើសកាតនេះបានសូមទាក់ទងមកកាន់លេខខាងក្រោមដោយអនុគ្រោះ
Tel: 093 666 635
ខុសគ្នា
មែនតើស!
កាតនេះ អ្នកគ្រូអារ
ពណ៌ទឹកក្រូចឲ្យមកខ្ញុំ
ពេលដកលុយកម្ចី


អាឡូ ជម្រាបសួរ! មានអ្នកខលមកប្រាប់ខ្ញុំថា ខាងអ្នកគ្រូមានកម្មវិធីបញ្ចុះតម្លៃលើចំនួនបងប្រចាំខែមែនទេ!?


គ្រឹះស្ថានពណ៌ទឹកក្រូចសូមជម្រាបសួរ
មិនមានកម្មវិធីបែបនេះទេអ្នកបង! អរគុណដែលបានខលមកសួរនាំ


អាចជាសកម្មភាពឆបោក!
សូមអ្នកបងប្រយ័ត្នប្រយែង
យកល្អ
អ្នកបងតាមដាន
បណ្តាញសង្គមយើងខ្ញុំ
ដើម្បីទទួលបានព័ត៌មាន
ទាន់ហេតុការណ៍
ចេះសួរទាន់
កុំអីស្ដេ!

**ចំណុចគួរចងចាំ**

- ក្រៅពីលេខរបស់មន្ត្រីឥណទាន គប្បីរក្សាទុកលេខសេវាបម្រើអតិថិជនរបស់ស្ថាប័ន និងតាមដានព័ត៌មាន នៅលើបណ្តាញសង្គមផ្លូវការរបស់ស្ថាប័ន ។
- ពន្យារពេលក្នុងការសម្រេចចិត្ត ដើម្បីពិភាក្សាជាមួយគ្រួសារ ឬស្ថាប័នដែលពាក់ព័ន្ធ ។

ជនរងគ្រោះដោយសារកម្ចីក្រៅផ្លូវការ និងខុសច្បាប់ អាចរាយការណ៍មកកាន់អគ្គស្នងការនគរបាលជាតិ តាមរយៈទូរសព្ទលេខ **023 72 68 22**



**ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសារអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារដំណើរការដាក់ស្នើរកម្ចីផលិតផលកម្ចី និងសារអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធិភាព ។

យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។

ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់
ហ្វឺស ហ្វាយនែន ឬតាមរយអ៊ីម៉ែល
infor@firstfiance.com.kh យើងខ្ញុំនឹងត្រូវពិនិត្យហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទ ឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអានផ្សេងទៀត ។


នាំមកជូនដោយ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ហ្វឺស ហ្វាយនែន ភីអិលស៊ី

FIRST FINANCE

គេហទំព័រ ហ្វឺស ហ្វាយនែន
www.firstfinance.com.kh